ចលនាខ្មែរដើម្បីប្រជាធិបតេយ្យ

**Khmer Movement For Democracy**

Organize the Movement * Educate the Public * Mobilize the People

០៧ មករា ២០២៥

### កម្ពុជាមានលទ្ធភាពធ្វើឲ្យប្រសើរឡើងដើម្បីទទួលបានឱកាសធ្វើពាណិជ្ជកម្មឡើងវិញ ប្រសិនបើទម្លាក់ការចោទប្រកាន់លើលោក រ៉ុង ឈុន

កាលពីថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤, ព្រះរាជអាជ្ញាររង លោក សេង ហៀង បានចេញដីកាកោះហៅ លោក រ៉ុង ឈុន ជាអតីតប្រធានសហភាព
សហជីពកម្ពុជា និងជាអតីតប្រធានសមាគមគ្រូបង្រៀនកម្ពុជាឯករាជ្យ ហើយធ្លាប់ជាអតីតសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតកូតា
សង្គ្រោះជាតិ ដែលបច្ចុប្បន្នជាទីប្រឹក្សាជាន់ខ្ពស់គណបក្សកម្លាំងជាតិ ឲ្យចូលរួមសវនាការជាកំហិតនៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៥ ដែលការណ៍
នេះកាន់តែធ្វើឲ្យមានការរាំងស្ទះដល់ការអភិវឌ្ឍសេដ្ឋកិច្ចកម្ពុជា ជាពិសេសការវិនិយោគទុនពី បណ្តាប្រទេសលោកសេរី ពីព្រោះលោក រ៉ុង ឈុន
ជាតួអង្គយ៉ាងសំខាន់ក្នុងការរួមចំណែកលើកស្ទួយសិទ្ធិសហជីព និងសិទ្ធិមនុស្សនៅកម្ពុជា។

គូសបញ្ជាក់ផងដែរថា កាលពីថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ២០២០ អាជ្ញាធរកម្ពុជាបានចាប់ខ្លួនលោក រ៉ុង ឈុន ទាំងយប់ បញ្ជូនទៅដាក់ពន្ធនាគារ
បន្ទាប់មកគាត់ត្រូវបានកាត់ឱ្យមានទោសពីរឆ្នាំ ពីបទ “ញុះញង់បង្កឲ្យមានភាពវឹកវរ ដល់សន្តិសុខសង្គម” ពាក់ព័ន្ធនឹងការបញ្ចេញមតិអំពីការ
បោះបង្គោលព្រំដែនរវាកម្ពុជា-វៀតណាម ហើយត្រូវបានដោះលែង កាលពីថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១ បន្ទាប់ពីជាប់ពន្ធនាគារអស់រយៈពេល
១៥ខែ និង ១១ថ្ងៃ ដោយទោសដែលនៅសេសសល់ត្រូវព្យួរទោសសាកល្បងរយៈពេល ៣ឆ្នាំ។ ទន្ទឹមនឹងនេះ លោក ស៊ុន ចន្ធី ប្រធានគណបក្ស
កម្លាំងជាតិ ត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគារពីរឆ្នាំ និងដកសិទ្ធិបោះឆ្នោត និងឈរឈ្មោះឲ្យគេបោះឆ្នោតអស់មួយជីវិត កាលពីចុងខែធ្នូ
ឆ្នាំ២០២៤។

ព្រឹត្តិការណ៍ទាំងនេះ បានកើតឡើងនៅក្នុងបរិបទភូមិសាស្រ្តនយោបាយមិនប្រាកដប្រជា ហើយការត្រឡប់មកកាន់តំណែងប្រធានាធិបតីលើកទីពីរ
របស់លោក ដូណាល់ ត្រាំ ទំនងជាបង្កើតហានិភ័យលើបន្ទុកពន្ធដ៏ធ្ងន់ធ្ងរសម្រាប់ទំនិញនាំចូលអាមេរិកពីសំណាក់ប្រទេសចិន និងប្រទេសដទៃ
ទៀត។ ការណ៍នេះ បង្កើតទាំងហានិភ័យ និងឱកាសសម្រាប់កម្ពុជា។ ជាបទពិសោធន៍ កាលពីអាណត្តិដំបូងរបស់ប្រធានាធិបតី ដូណាល់ ត្រាំ បាន
ផ្តល់ឱកាសដល់ប្រទេសអាស៊ីផ្សេងទៀតជំនួសប្រទេសចិន ជាអ្នកផ្គត់ផ្គង់ទៅសហរដ្ឋអាមេរិក ដែលជាគំរូមួយអាចនឹងកើតឡើងម្តងទៀត។ ជាការ
ពិត ប្រទេសដែលត្រូវបានគេមើលឃើញថាមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយប្រទេសចិនក៏អាចប្រឈមមុខនឹងការយកពន្ធយ៉ាងខ្លាំងផងដែរ។

កម្ពុជាក្នុងដំណាក់កាលសំខាន់នេះត្រូវរក្សា និងពង្រីកលទ្ធភាពចូលទីផ្សារអន្តរជាតិឱ្យបានជាអតិបរមា។ ប្រទេសកម្ពុជាមានគោលបំណងចាក
ចេញពីស្ថានភាពប្រទេសអភិវឌ្ឍន៍តិចតួច (LDC) ដូចដែលបានកំណត់ដោយអង្គការសហប្រជាជាតិនៅឆ្នាំ 2029។ សហភាពអឺរ៉ុបគឺជាទីផ្សារធំ
ទីពីររបស់កម្ពុជាបន្ទាប់ពីសហរដ្ឋអាមេរិក។ កម្ពុជាបានបាត់បង់សិទ្ធិអនុគ្រោះពន្ធចំនួន 20% ទៅកាន់ទីផ្សារអ៊ឺរ៉ុប ក្រោមគម្រោងអ្វីៗគ្រប់យ៉ាងលើក
លែងតែអាវុធ (EBA) ក្នុងឆ្នាំ 2020 ដោយហេតុផលជាច្រើនរួមទាំងកំណត់ត្រាសិទ្ធិការងារមិនល្អរបស់ប្រទេសនេះ។

ដូច្នេះការបើកលំហរសិទ្ធិសេរីភាពសហជីព សិទ្ធិនយោបាយ និងសង្គមស៊ីវិល ដោយគ្មានការរំខាន នឹងធ្វើឲ្យមានវឌ្ឍនភាពនៃការនាំចេញផលិតផល
របស់កម្ពុជានាពេលអនាគត។ សម្លៀកបំពាក់ ស្បែកជើង កាបូប និងផលិតផលសំខាន់ៗ ដែលនាំចេញពីប្រទេសកម្ពុជា ទៅកាន់ទីផ្សារប្រទេសសេរី
ជាសក្ខីភាពមិនអាចប្រកែកបាន។ កាលពីខែកញ្ញា ក្រុមម៉ាកយីហោចំនួន 18 បានជំរុញឱ្យរដ្ឋាភិបាលកម្ពុជាលុបចោលការធ្វើសវនកម្មរបស់ខ្លួន
ចំពោះមជ្ឈមណ្ឌលសម្ព័ន្ធភាពការងារ និងសិទ្ធិមនុស្ស (CENTRAL) ហើយបញ្ចប់សំណុំរឿងព្រហ្មទណ្ឌប្រឆាំងនឹងអ្នកគ្រប់គ្រងកម្មវិធី
CENTRAL លោក ឃុន ថារ៉ូ។ បញ្ហារវាងរដ្ឋាភិបាលកម្ពុជា និង CENTRAL បានកើតឡើងបន្ទាប់ពីការចេញរបាយការណ៍មួយរបស់
CENTRAL ស្តីពី “ឧបសគ្គរារាំងភាពជាតំណាង៖ សេរីភាពសហជីពក្នុងប្រទេសកម្ពុជា”។ ការសម្រេចរបស់តុលាការក្នុងការគោរពសិទ្ធិ
នយោបាយលោក រ៉ុង ឈុន នឹងជះផលវិជ្ជមានចំពោះការយល់ឃើញរបស់សហគមន៍អន្តរជាតិទៅនឹងស្ថានភាពនយោបាយកម្ពុជា។ កម្ពុជាត្រូវ
ត្រៀមលក្ខណៈសម្រាប់ការប្រកួតប្រជែង ដើម្បីខ្លួនមានសមត្ថភាពទទួលជោគជ័យ មិនមែនសម្រាប់ភាពឯកោ ដែលនាំឲ្យអន្តរាយនោះទេ។

111 Fitchburg Rd, Ayer, MA 01432
contact@khmermovementfordemocracy.org
Khmermovementfordemocracy.org
+1 702 808 0337

N-O